**FRONT**

hovid

# កូឡូដ្យូម
# COLODIUM

20132

I - <u>រូបភាពឱសថ</u> :

- ជាឱសថប្រភេទកាប់ស៊ុល សំរាប់លេប
- ១ ប្រអប់ មាន ១០ បន្ទះ ក្នុង ១ បន្ទះ មាន ១០ កាប់ស៊ុល

II - <u>សមាសធាតុផ្សំ</u> : ក្នុង ១ គ្រាប់ មាន :

- Loperamide Hydrochloride ………….............. 2 mg

III - <u>គុណភាពព្យាបាល</u> :

- ជាប្រភេទឱសថ ដែលមានប្រសិទ្ធភាពប្រឆាំងជម្ងឺរាក ដោយទប់ស្កាត់ចលនាកន្ត្រាក់របស់ពោះវៀន ឬសាច់ដុំរលោង
- ឱសថនេះប្រើសំរាប់កាត់បន្ថយជម្ងឺរាកធ្ងន់ធ្ងរ ដែលគ្មានប្រភពច្បាស់លាស់ ឬជម្ងឺរាករ៉ាំរ៉ៃរួមផ្សំនិងជម្ងឺរលាកពោះវៀន ។ ជាការប្រសើរដូចគ្នាក្នុងការកាត់បន្ថយបរិមាណលាមកដោយចោះផ្នែកចុងពោះវៀនតូចដើម្បីបញ្ចេញលាមកមកក្រៅ ។

IV - <u>ហាមប្រើ</u> :

- ចំពោះកុមារអាយុក្រោម ៦ ឆ្នាំ និងអ្នកជម្ងឺរលាកពោះវៀនធំធ្ងន់ធ្ងរ
- អ្នកមានជម្ងឺរាករួមផ្សំនឹងជម្ងឺរលាកពោះវៀនដែលមានសារធាតុម្យ៉ាងពាសនៅលើភ្នាសពោះវៀន ដោយការប្រើពួកឱសថអង់ទីប៊ីយ៉ូទីក ។

V - <u>ការប្រុងប្រយ័ត្ន</u> :

- ឱសថនេះហាមប្រើចំពោះកុមារអាយុក្រោម ៦ ឆ្នាំ ពីព្រោះវាអាចបណ្តាលឱ្យមានគ្រោះថ្នាក់រហូតដល់ស្លាប់
- នៅពេលប្រើឱសថនេះត្រូវប្រើពួកឱសថដែលមានសារធាតុអេឡិចត្រូលីត ( សេរ៉ូម ) ដើម្បីជំនួសជាតិទឹក និងសារធាតុទាំងនេះ ដែលបាត់បង់ដោយជម្ងឺរាក
- ឱ្យអ្នកជម្ងឺផឹកទឹកឱ្យបានច្រើន ឬប្រើ SRO
- ការប្រើឱសថ ដែលទប់ស្កាត់ចលនាកន្ត្រាក់របស់ពោះវៀនអាចធ្វើឱ្យទប់ស្កាត់ជាតិទឹកនៅក្នុងពោះវៀន ដែលអាចបណ្តាលឱ្យការបាត់បង់ជាតិទឹកកាន់តែធ្ងន់ធ្ងរ និងមានការថយចុះនូវពួកសារធាតុអេឡិចត្រូលីតនៅក្នុងឈាម
- ក្នុងករណីសភាពបាត់បង់ជាតិទឹកធ្ងន់ធ្ងរ ឬបាត់បង់ពួកអេឡិចត្រូលីតច្រើនត្រូវបន្តប្រើ Loperamide រហូតកំរិតជាតិទឹក និងអេឡិចត្រូលីតកើនមកត្រឹមកំរិតធម្មតាវិញ
- ចំពោះស្ត្រីមានផ្ទៃពោះ និងស្ត្រីបំបៅកូន មុនប្រើឱសថនេះត្រូវពិគ្រោះជាមួយគ្រូពេទ្យ
- នៅពេលប្រើឱសថនេះត្រូវប្រុងប្រយ័ត្ន និងតាមដានចំពោះផលរំខានមួយចំនួនដូចតទៅ : ទល់លាមក បាត់បង់ជាតិទឹក រាកដោយសារពួកមេរោគ ខ្សោយមុខងារថ្លើម

* <u>ផលរំខានខ្លះៗ</u> :

- ឈឺពោះ និងវិបត្តិក្រពះ ពោះវៀន ( ពោះវៀនធំមានទំហំធំជាងធម្មតា )
- ស្ងួតមាត់
- ធីងធោង អស់កម្លាំង ប្រព័ន្ធប្រសាទកណ្តាលថយចុះ
- ចង្អោរ ក្អួត មិនឃ្លានអាហារ
- ស្បែកឡើងក្រហម និងមានកន្ទួល
- ទល់លាមក

20132

VICOL07-4 (CAM)

487

**BACK**

**COLODIUM**

20132

* ការប្រើលើសកំរិត :

- បណ្ដាលឱ្យ : ចង្អោរ ឈឺចុងដង្ហើម ទល់លាមក ធីងធោង សភាពងោកងុយ បាត់បង់ស្មារតី និងសន្លប់
- ការព្យាបាល : ត្រូវបញ្ជូនអ្នកជម្ងឺទៅកាន់មន្ទីរពេទ្យដើម្បីសង្គ្រោះជាបន្ទាន់ ។

* ការរក្សាទុក :

- ទុកនៅសីតុណ្ហភាពក្រោម៣0 អង្សាសេ កុំឱ្យត្រូវសំណើម   និងទុកឱ្យផុតពីដៃក្មេង ។

VI - កំរិតនិងរបៀបប្រើ :

- មនុស្សពេញវ័យ : ប្រើពី ៦ ទៅ ៨ម.ក្រ ក្នុង១ថ្ងៃ ឬអាចបង្កើនកំរិតប្រើរហូតដល់ ១៦ម.ក្រ ក្នុង១ថ្ងៃ ( ដោយចែកជា ២ ទៅ ៣ដង ក្នុង១ថ្ងៃ)
- កុមារអាយុពី ៦ ទៅ ៨ ឆ្នាំ : ប្រើ ៤.0 ម.ក្រ ក្នុង ១ថ្ងៃ ( ដោយចែកជា ២ ទៅ ៣ដង ក្នុង ១ថ្ងៃ)
- កុមារអាយុពី ៩ ទៅ ១២ ឆ្នាំ : ប្រើ ៦.0 ម.ក្រ ក្នុង ១ថ្ងៃ ( ដោយចែកជា ២ ទៅ ៣ដង ក្នុង ១ថ្ងៃ) ។

* សំគាល់: កុមារអាយុក្រោម ៦ ឆ្នាំ ហាមប្រើឱសថនេះ ។

VII - លេខបញ្ជិកាឱសថ : CAM $R_3$ 0537IP-97

VIII - ផលិតដោយ : **HOVID Bhd.**
121, Jalan Tunku Abdul Rahman (Jalan Kuala Kangsar), 30010 Ipoh, Perak, Malaysia.
Lot 56442, 7 ½ Miles, Jalan Ipoh/Chemor, 31200 Chemor, Perak, Malaysia.

បានបកប្រែនិងត្រួតពិនិត្យដោយនាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង ។

20132